ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៨៩០ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ ២០១៣

# ប្រកាស
## ស្តីពីការដាក់ឱ្យអនុវត្ត
## គោលការណ៍ណែនាំស្តីពីការធ្វើផែនការសាច់ប្រាក់

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី របបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០១៩ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែមនិងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីការកែសម្រួលការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

/.

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញសេចក្តីសម្រេចលេខ៥៦ សសរ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៧ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញប្រកាសលេខ ២១៨ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការបង្កើតគណៈកម្មាធិការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញប្រកាសលេខ ១២០ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការកែសម្រួលប្រកាសលេខ២១៨ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការបង្កើតគណៈកម្មាធិការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញប្រកាសលេខ ២២៥ សហវ.ប្រក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៤ ស្តីពីការបង្កើតគណៈកម្មការតាមដានការអនុវត្តន៍ថវិកានិងគ្រប់គ្រងសាច់ប្រាក់
- បានឃើញប្រកាសលេខ ៥៩២ សហវ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មការតាមដានការអនុវត្តន៍ថវិកានិងគ្រប់គ្រងសាច់ប្រាក់
- បានឃើញប្រកាសលេខ ៦១៥ សហវ.ប្រក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១ ស្តីពីការផ្ទេរអង្គភាពគ្រប់គ្រងសាច់ប្រាក់ ទៅស្ថិតនៅក្នុងអគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
- បានឃើញប្រកាសលេខ ៦១៧ សហវ.ប្រក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មការបច្ចេកទេសគ្រប់គ្រងសាច់ប្រាក់ ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានរតនាគារជាតិ។
- បានឃើញប្រកាសលេខ២១១ សហវ.ប្រក ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។
- បានឃើញប្រកាសលេខ៥៨៨ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការផ្ទេរមុខងារបន្ថែមឱ្យទៅអង្គភាពគ្រប់គ្រងសាច់ប្រាក់ នៃអគ្គនាយកដ្ឋានរតនាគារជាតិ
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## <u>សម្រេច</u>

**ប្រការ ១ :** ត្រូវបានដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការធ្វើផែនការសាច់ប្រាក់ ដល់ក្រសួង ស្ថាប័នចំណូល ចំណាយ អង្គភាពប្រមូលចំណូល អង្គភាពពាក់ព័ន្ធ និងអង្គភាពក្រោមឱវាទទាំងអស់ ដូចមានភ្ជាប់ជាមួយប្រកាសនេះ។

**ប្រការ ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៣ :** អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប្រធានអង្គភាពគ្រប់គ្រងសាច់ប្រាក់ ប្រធានគណៈកម្មការបច្ចេកទេសគ្រប់គ្រងសាច់ប្រាក់ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

<u>ចម្លងជូន:</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- គ្រប់ក្រសួង ស្ថាប័ន និងអង្គភាពក្រោមចំណុះ
- អគ្គនាយកដ្ឋានរតនាគារជាតិ
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- អគ្គនាយកដ្ឋានពន្ធដារ
- គ្រប់នាយកដ្ឋាន នៃ កសហវ
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត
- រតនាគាររាជធានី ខេត្ត

  " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# គោលការណ៍ណែនាំ

# ស្តីពី

# ការធ្វើផែនការសាច់ប្រាក់



ឆ្នាំ២០១៣

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជាបានបោះជំហានយ៉ាងស្វាហាប់ក្នុងការធ្វើកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដើម្បីធ្វើការកែលំអការប៉ាន់ស្មានលំហូរសាច់ប្រាក់ឲ្យកាន់តែសុក្រឹត្យនិងគ្រប់គ្រងធនធានសាច់ប្រាក់របស់ខ្លួនឲ្យកាន់តែមានប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធ និងធ្វើការគ្រប់គ្រងលើការចំណាយថវិកាកាន់តែមានតម្លាភាព។ ដើម្បីដាក់បញ្ចូលទៅក្នុងប្រព័ន្ធនិងពង្រឹងនូវកិច្ចប្រឹងប្រែងទាំងនេះ និងដើម្បីបង្កើតឡើងនូវគោលនយោបាយ នីតិវិធីនិងប្រព័ន្ធ សម្រាប់ប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់ដើម្បីបង្កើតបាននូវការព្យាករណ៍លំហូរសាច់ប្រាក់ និងសមតុល្យសាច់ប្រាក់ចុងគ្រាបានត្រឹមត្រូវនិងទាន់ពេលវេលានៅគណនីទោលរតនាគារដូចមានចែងនៅក្នុងប្រកាសលេខ៦១៧ សហវ.ប្រក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានសម្រេចដាក់ចេញនូវគោលការណ៍ណែនាំស្តីអំពីការធ្វើផែនការសាច់ប្រាក់ដែលនឹងត្រូវបានអនុវត្តនៅតាមបណ្តាក្រសួង ស្ថាប័ននិងសហគ្រាសសាធារណៈទាំងអស់។

ភាពជោគជ័យនៃប្រព័ន្ធណាមួយ អាស្រ័យដោយមានការបណ្តុះបណ្តាលគ្រប់គ្រាន់សម្រាប់គ្រប់កម្រិត នៃអ្នកប្រើប្រាស់ប្រព័ន្ធទាំងអស់នឹងពឹងផ្អែកទៅលើការពិភាក្សាជាប្រចាំរវាងភាគីទាំងអស់ដែលមានការពាក់ព័ន្ធនៅក្នុងការប្រើប្រាស់ប្រព័ន្ធនេះ។ អគ្គនាយកដ្ឋានរតនាគារជាតិ កំពុងតែធ្វើការរៀបចំចាត់ចែងដើម្បីផ្តល់នូវការបណ្តុះបណ្តាលសមស្របទៅដល់សិក្ខាកាមទាំងអស់ដែលពាក់ព័ន្ធនៅក្នុងដំណើរការនៃការធ្វើផែនការសាច់ប្រាក់។

ជំហានបន្ទាប់មកទៀតទាក់ទងនឹងការបង្កើតឲ្យមាននូវការពិភាក្សាជាប្រចាំរវាងភាគីទាំងអស់ដែលពាក់ព័ន្ធទៅនឹងការអនុវត្តដំណើរការធ្វើផែនការសាច់ប្រាក់នេះគឺទាមទារឲ្យមាននូវកិច្ចសហប្រតិបត្តិការនិងការពិភាក្សាគ្នាជាប្រចាំរវាងអគ្គនាយកដ្ឋានរតនាគារជាតិជាមួយនឹងក្រសួង ស្ថាប័នផ្សេងៗ និងសហគ្រាសសាធារណៈដទៃទៀត។ ការពិភាក្សាគ្នាទៀងទាត់បង្កើតឲ្យមាននូវការយល់ដឹងរួមគ្នាអំពីកម្រិតនិងតម្រូវការចាំបាច់ដើម្បីសម្រេចបាននូវគោលដៅទូទៅរបស់រាជរដ្ឋាភិបាល។ ខ្ញុំមានការជឿជាក់ថា ដោយមានកិច្ចសហប្រតិបត្តិការពីសំណាក់ឯកឧត្តម លោកជំទាវ លោកលោកស្រីទាំងអស់ ភារកិច្ចនេះនឹងបានសម្រេចនៅក្នុងពេលខាងមុខដ៏ខ្លីហើយនឹងបន្តទៅក្នុងអនាគត ដើម្បីធ្វើឲ្យក្លាយទៅជាប្រព័ន្ធមួយដែលមានភាពជោគជ័យដើម្បីលើកកំពស់នូវការផ្តល់សេវាដល់ប្រជាពលរដ្ឋកម្ពុជា។

រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

# ការធ្វើផែនការសាច់ប្រាក់

## I. សេចក្តីផ្តើម

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំផែនការលំហូរចូលនិងលំហូរចេញសាច់ប្រាក់ ដើម្បីធ្វើការគ្រប់គ្រងនូវធនធានសាច់ប្រាក់របស់ខ្លួនឲ្យកាន់តែមានប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិ ដើម្បីតាមដានចំណូល និងធ្វើការគ្រប់គ្រងលើចំណាយថវិកា។ ការធ្វើផែនការសាច់ប្រាក់នឹងត្រូវបានអនុវត្តដោយគណៈកម្មការបច្ចេកទេសគ្រប់គ្រងសាច់ប្រាក់(**គបគស**) ស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាសេនាធិការបច្ចេកទេសឲ្យគណៈកម្មការតាមដានការអនុវត្តថវិកា និងគ្រប់គ្រងសាច់ប្រាក់(**គថស**)។ គណៈកម្មការ **គបគស** ត្រូវបង្កើតឡើងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គណៈកម្មការបច្ចេកទេសគ្រប់គ្រងសាច់ប្រាក់មានភារកិច្ចដូចខាងក្រោម៖

១.កសាងគោលនយោបាយ នីតិវិធីនិងប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់ ដើម្បីធ្វើការព្យាករណ៍លំហូរសាច់ប្រាក់និងការព្យាករណ៍សមតុល្យសាច់ប្រាក់ចុងថ្ងៃនៅក្នុងគណនីទោលរតនាគារឲ្យមានភាពត្រឹមត្រូវនិងទាន់ពេលវេលា

២.ធ្វើការសម្របសម្រួល ប្រមូលនិងផ្ទៀងផ្ទាត់ទិន្នន័យដែលបានព្យាករណ៍អំពីចំណូលនិងចំណាយសាធារណៈពីនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងស្ថាប័នផ្សេងៗទៀតដោយរួមបញ្ចូលទាំងរាជធានីខេត្តក្រុងស្រុកខណ្ឌឃុំសង្កាត់ទូទាំងប្រទេស

៣.ធ្វើការព្យាករណ៍ចំណូលចំណាយសាច់ប្រាក់ប្រចាំថ្ងៃ ដោយធ្វើការប្រជុំពិភាក្សារៀងរាល់ថ្ងៃដើម្បីពិនិត្យមើលសមតុល្យសាច់ប្រាក់ជាក់ស្តែងចុងថ្ងៃនៅក្នុងគណនីទោលរតនាគារ ដោយធានាថាសាច់ប្រាក់នឹងត្រូវប្រើប្រាស់ឲ្យមានប្រសិទ្ធភាពនិងចំគោលដៅដើម្បីអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យមានប្រសិទ្ធិភាព

៤. រៀបចំនិងពិនិត្យឡើងវិញនូវការព្យាករណ៍លំហូរសាច់ប្រាក់៣ខែរំកិល និងបង្កើតចេញនូវការព្យាករណ៍សាច់ប្រាក់ប្រចាំសប្តាហ៍ប្រចាំខែ ចំពោះនាយកដ្ឋានគន្លឹះមួយចំនួនរបស់ក្រសួងស្ថាប័ន រួមទាំងអគ្គនាយកដ្ឋាន/នាយកដ្ឋានប្រមូលចំណូលនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៥. រៀបចំនិងពិនិត្យឡើងវិញចំណូលដែលប្រមូលបាន និងចំណាយដែលបានអនុវត្តដោយធ្វើការប្រៀបធៀបជាមួយផែនការលំហូរសាច់ប្រាក់ប្រចាំឆ្នាំនិងជាមួយការព្យាករណ៍លំហូរសាច់ប្រាក់៣ខែរំកិល

៦. ធ្វើការព្យាករណ៍និងពិនិត្យឡើងវិញនូវស្ថានភាពសាច់ប្រាក់សុទ្ធ (ដូចជាសរុបសមតុល្យសាច់ប្រាក់ចុងថ្ងៃនៅក្នុងគណនីទោលរតនាគារ) សម្រាប់រយៈពេល១ខែ ១ត្រីមាសនិង១ឆ្នាំ

៧. រៀបចំរបាយការណ៍ជូន **គថស** ជារៀងរាល់ចុងខែស្តីពីការព្យាករណ៍លំហូរសាច់ប្រាក់ ដូចមានចែងក្នុងចំណុចទី៣ ទី៤ ទី៥ និងទី៦ ខាងលើ ហើយលើកជូនជាយោបល់ស្តីពីវិធានការណ៍ចាំបាច់ទាំងឡាយ ដើម្បីរក្សាលំនឹងសមតុល្យសាច់ប្រាក់ឲ្យស្ថិតនៅក្នុងចន្លោះមួយដែលបានកំណត់ដោយ **គថស** ក្នុងនោះរួមមានទាំងការបោះផ្សាយប័ណ្ណរតនាគារផងប្រសិនបើមាន

៨. ពិនិត្យជាបន្ទាន់នូវតម្រូវការនានា ដែលកំពុងមាននៅក្រៅប្រព័ន្ធផែនការលំហូរសាច់ប្រាក់ ដើម្បីរាយការណ៍ជូន **គថស** ឲ្យបានសមស្របនិងទាន់ពេលវេលា។

គោលការណ៍ណែនាំនេះនឹងជួយដល់ **គបគស** នៅក្នុងការអនុវត្តភារកិច្ចរបស់ខ្លួនដូចមានចែងខាងលើដែលធ្វើឲ្យគណៈកម្មការនេះ អាចប្រមូលបាននូវទិន្នន័យចំណូលចំណាយសាធារណៈ ដើម្បីធ្វើការផ្ទៀងផ្ទាត់និងព្យាករណ៍សាច់ប្រាក់ប្រចាំថ្ងៃ។

ដើម្បីសម្រេចបាននូវគោលដៅខាងលើអគ្គនាយកដ្ឋានរតនាគារជាតិតាមរយៈ **គបគស** នឹងបង្កើតឡើងនូវការព្យាករណ៍សាច់ប្រាក់សរុបរួម(តារាងឧបសម្ព័ន្ធទី១កនិងទី១ខ) នៅរៀងរាល់ដើមឆ្នាំនៃឆ្នាំគ្រប់គ្រងថវិកានីមួយៗ តាមរយៈការប្រមូលនូវលំហូរសាច់ប្រាក់គ្រោងទុករបស់ក្រសួង ស្ថាប័នដែលប្រមូលចំណូល(ត្រូវបានរាយការណ៍នៅក្នុងតារាងឧបសម្ព័ន្ធទី២)និងការចំណាយតាមក្រសួង ស្ថាប័ន(ត្រូវបានរាយការណ៍នៅក្នុងតារាងឧបសម្ព័ន្ធទី៣)រួមទាំងក្រសួង ស្ថាប័នប្រមូលចំណូល។ដើម្បីធានាឲ្យមាននូវភាពពេញលេញនិងដើម្បីធ្វើឲ្យរដ្ឋាភិបាលអាចធ្វើការកំណត់អំពីតម្រូវការលំហូរសាច់ប្រាក់របស់ខ្លួនបាននោះទិន្នន័យនេះនឹងត្រូវរួមបញ្ចូលទិន្នន័យរបស់ក្រសួងស្ថាប័នទាំងអស់។ ផែនការសាច់ប្រាក់ដែលត្រូវបានបង្កើតឡើងតាមរបៀបនេះនឹងត្រូវបានប្រើប្រាស់ដោយធ្វើការបែងចែកនិងបញ្ចេញសាច់ប្រាក់ប្រចាំខែទៅឲ្យបណ្តាក្រសួង ស្ថាប័ន។ តារាងឧបសម្ព័ន្ធទី៤ គឺជាតារាងសង្ខេបអំពីការព្យាករណ៍សាច់ប្រាក់លំអិតមាននៅក្នុងតារាងឧបសម្ព័ន្ធទី១ ដែលបង្ហាញអំពីការព្យាករណ៍សរុបនៃលំហូរសាច់ប្រាក់ចេញ-ចូល ព្រមទាំងឱនភាពនិងអតិរេកសាច់ប្រាក់ដែលត្រូវបានព្យាករណ៍ទុកក្នុងខែនីមួយៗ។

## II. សេចក្តីណែនាំលំអិតសម្រាប់ក្រសួង ស្ថាប័ននីមួយៗ

១. គ្រប់ក្រសួង ស្ថាប័នទាំងអស់ត្រូវធ្វើការជូនដំណឹងដល់ **គបគស** អំពីតម្រូវការសាច់ប្រាក់របស់ខ្លួនដោយធ្វើការលំអិតទៅតាមខែនីមួយៗ [1] និងត្រូវផ្តល់របាយការណ៍ពីរដាច់ដោយឡែកពីគ្នា(តារាង

[1] ដូចដែលត្រូវបានបង្ហាញនៅក្នុងកាលវិភាគក្នុងតារាងឧបសម្ព័ន្ធទី៧។

ឧបសម្ព័ន្ធទី២និងទី៣)។តារាងឧបសម្ព័ន្ធទី២ គឺត្រូវរាយការណ៍អំពីលំហូរនៃចំណូលប្រចាំខែ។ របាយការណ៍នេះ ត្រូវរួមបញ្ចូលទាំងចំណូលពន្ធដែលអាចត្រូវបានប្រមូលដោយស្ថាប័នប្រមូលចំណូល និងចំណូលមិនមែនសារពើពន្ធដែលត្រូវបានប្រមូលដោយក្រសួងស្ថាប័នផ្សេងៗទៀត។ រាល់ចំណាយទាំងអស់នឹងត្រូវបានរាយការណ៍នៅក្នុងតារាងឧបសម្ព័ន្ធទី៣។

២. ក្រសួង ស្ថាប័ននីមួយៗត្រូវផ្ញើជូនប្រធាន **គបគស<u>ជាទៀងរាល់ឆ្នាំយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ខែវិច្ឆិកា</u>** នូវការព្យាករណ៍អំពីការចំណាយសាច់ប្រាក់ប្រចាំខែរបស់ខ្លួនសម្រាប់ឆ្នាំបន្ទាប់ដូចមានគំរូនៅក្នុងតារាងឧបសម្ព័ន្ធទី៣ ដោយគោរពទៅតាមនីតិវិធីដែលត្រូវបានបញ្ជាក់លំអិតនៅក្នុងជំហានទី១ រហូតដល់ជំហានទី៥ នៃគោលការណ៍ណែនាំនេះ។ គ្រប់ក្រសួង ស្ថាប័នក៏ត្រូវធ្វើការព្យាករណ៍ចំណូលដែលត្រូវប្រមូលបាននៅក្នុងកាលបរិច្ឆេទតែមួយដោយប្រើប្រាស់នូវតារាងឧបសម្ព័ន្ធទី២[2]។

ដើម្បីសម្រេចបាននូវការព្យាករណ៍សាច់ប្រាក់ឲ្យមានប្រសិទ្ធភាពខ្ពស់ ក្រសួង ស្ថាប័នត្រូវអនុវត្តនូវជំហានបន្តបន្ទាប់ដូចខាងក្រោម៖

**ជំហានទី១:**

**ក.** ក្រសួង ស្ថាប័នត្រូវធ្វើការបូកសរុបចំណាយលំអិតប្រចាំខែដែលអាចកើតមានឡើងសម្រាប់ឆ្នាំទាំងមូលពីអង្គភាពចំណាយនីមួយៗដែលស្ថិតនៅក្នុងការគ្រប់គ្រងរដ្ឋបាលរបស់ខ្លួននិងដោយផ្អែកទៅលើផែនការលទ្ធកម្មប្រចាំឆ្នាំឲ្យបានមុនថ្ងៃទី១ ខែវិច្ឆិកា នៃឆ្នាំនីមួយៗ។ ការព្យាករណ៍ទាំងនេះត្រូវផ្អែកទៅលើសកម្មភាពដែលបានដំណើរការរួចហើយនិងសកម្មភាពដែលអាចត្រូវបានអនុវត្តនៅក្នុងដំណាក់កាលខាងមុខនៃឆ្នាំ។ ឧទាហរណ៍ គេអាចមានសកម្មភាពដូចជា៖ ការជួសជុលអាគារដែលបានដំណើរការរួចហើយឬតម្រូវការចំណាយរដ្ឋបាលជាប្រចាំ(ឧ.ការទិញសម្ភារៈការិយាល័យ)។ សម្រាប់ប្រាក់បៀវត្សរ៍គឺត្រូវគិតបញ្ចូលទាំងប្រាក់បៀវត្សរ៍ជាមូលដ្ឋាននិងប្រាក់ឧបត្ថម្ភផ្សេងៗ។ ចំពោះប្រាក់បៀវត្សរ៍ដែលបានផ្ញើអាណត្តិមកអគ្គនាយកដ្ឋានរតនាគាររួចហើយតែនៅមិនទាន់បើកផ្តល់នោះប្រសិនបើមានក្រសួងស្ថាប័នមិនចាំបាច់ធ្វើផែនការទៀតទេ ព្រោះត្រូវបានដោះស្រាយជាច់ដោយឡែកដោយអគ្គនាយកដ្ឋានរតនាគារជាតិ ដោយមានការពិគ្រោះយោបល់ជាមួយនឹងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ខ.** នៅក្នុងករណីចំណាយដែលមិនមែនជាប្រាក់បៀវត្សរ៍តម្រូវការសាច់ប្រាក់សម្រាប់ខែនីមួយៗជាធម្មតាមិនមានលក្ខណៈទៀងទាត់ទេ។ ផ្ទុយទៅវិញគឺអាស្រ័យទៅលើតម្រូវការចំណាយជាក់ស្តែងរបស់

[2] នៅដំណាក់កាលក្រោយ បន្ទាប់ពីមានសមត្ថភាពគ្រប់គ្រាន់ហើយនោះប្រព័ន្ធព្យាករណ៍ដែលមានការកែលំអនឹងជួយបង្កជាធាតុចូលទៅក្នុងប្រព័ន្ធ។

ក្រសួងស្ថាប័ននីមួយៗ។ ដូច្នេះក្រសួង ស្ថាប័នចំណាយត្រូវធ្វើការព្យាករណ៍ឲ្យមានភាពប្រាកដប្រជាដោយធានាថា រាល់ការចំណាយទាំងអស់នៅក្នុងឥណទានថវិការបស់ខ្លួនត្រូវបានគ្របដណ្តប់ពេញលេញនៅក្នុងការព្យាករណ៍អំពីលំហូរសាច់ប្រាក់របស់ខ្លួន។

**គ.** ការរៀបចំផែនការចំណាយរបស់អង្គភាពចំណាយនីមួយៗ ត្រូវបានគ្រប់គ្រងនិងសម្របសម្រួលដោយក្រសួង ស្ថាប័នសាមីដូចខាងក្រោម៖

- ប្រើប្រាស់នូវមុខចំណាយអាទិភាពផ្ទៃក្នុងដើម្បីធ្វើការផ្ទៀងផ្ទាត់លទ្ធផលសកម្មភាពនិងបន្ទុករបស់ខ្លួន
- កាត់ចេញនូវសកម្មភាពទាំងឡាយណាដែលមិនបានដាក់បញ្ចូលនៅក្នុងថវិកាចុងក្រោយ
- កំណត់ពេលវេលាអនុវត្តន៍(ធ្វើការប៉ាន់ប្រមាណអំពីកាលបរិច្ឆេទចាប់ផ្តើមរយៈពេលអនុវត្តន៍និងកាលបរិច្ឆេទបញ្ចប់)
- ធ្វើការប៉ាន់ស្មានពេលវេលានៃតម្រូវការសាច់ប្រាក់ដែលពាក់ព័ន្ធនឹងខ្ទង់ចំណាយនីមួយៗ
- ត្រូវធានាថាការចំណាយសរុបស្ថិតនៅក្នុងរង្វង់ថវិកាដែលបានអនុម័ត(ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ/ច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ)។

**ឃ.** ចំណុចសំខាន់ៗមួយចំនួនដែលត្រូវធ្វើការរៀបចំផែនការសាច់ប្រាក់នោះគឺត្រូវ៖

- ផ្អែកលើសកម្មភាពដែលបានដាក់បញ្ចូលក្នុងថវិកាដែលបានអនុម័ត
- ផ្អែកលើពេលវេលានៃការចំណាយសាច់ប្រាក់ជាក់ស្តែង(មានន័យថាសកម្មភាពអាចត្រូវបានអនុវត្តលើសរយៈពេល៣ខែ ប៉ុន្តែការទូទាត់ត្រូវបានធ្វើឡើងនៅក្នុងខែទី៤)
- ការកំណត់ពេលវេលានៃសកម្មភាពនិងការកំណត់ពេលវេលានៃការចំណាយ គឺត្រូវគិតបញ្ចូលទាំងពេលវេលាដំណាក់កាលដំបូងដែលមិនទាន់មានការចំណាយនៅឡើយ(ឧ.លទ្ធកម្ម)។ ដូចគ្នានេះដែរ ការចំណាយធំៗ[3]គប្បីត្រូវបានប៉ាន់ស្មានប្រកបដោយការប្រុងប្រយ័ត្នដោយត្រូវគិតដល់កាលបរិច្ឆេទនៃការទូទាត់
- ផែនការចំណាយគប្បីមានភាពគ្រប់ជ្រុងជ្រោយដោយរួមបញ្ចូលនូវខ្ទង់ចំណាយដូចជា៖បុរេប្រទានរដ្ឋទេយ្យបុរេប្រទាន។ល។ ទៅតាមការចាំបាច់។

គម្រោងចំណាយមូលធនដែលកំពុងដំណើរការមានភាពខុសគ្នាទៅតាមតម្រូវការមូលនិធិនិងពេលវេលា។ គម្រោងទាំងនេះរួមមាន៖ គម្រោងផ្លូវស្ពានថ្នល់គម្រោងសាងសង់។ល។គម្រោងបែបនេះអាចត្រូវការពេលវេលាច្រើនឆ្នាំដើម្បីបញ្ចប់។ ហេតុដូច្នេះហើយការធានាចំណាយនិងតម្រូវការសាច់ប្រាក់ដើម្បី

[3] ការចំណាយធំអាចរាប់បញ្ចូលនូវការបង់ប្រាក់សម្រាប់ការជួលដី ការជួលផ្ទះ ការបង់ប្រាក់ទៅឱ្យស្ថាប័នអន្តរជាតិ ។ល។ ក៏ដូចជាការប្រមូលចំណូល ឧ.ចំណូលពន្ធដុលប្រចាំត្រីមាស (quarterly gross revenue tax)។

បញ្ចប់នូវគម្រោងទាំងនោះអាចត្រូវពន្យារពេលយូរអង្វែង។ ប៉ុន្តែការធានាចំណាយសម្រាប់តម្លៃគម្រោងទាំងមូលគឺអាចកើតមានឡើងភ្លាមៗនៅពេលដែលកិច្ចសន្យាត្រូវបានចុះហត្ថលេខា។ ការព្យាករណ៍អាចធ្វើឡើងច្រើនដង ដើម្បីធានាឲ្យមាននូវតុល្យភាពសាច់ប្រាក់សម្រាប់រ៉ាប់រងទៅលើទឹកប្រាក់សរុបនៃការធានាចំណាយ។ ដូច្នេះមានន័យថាដែនកំណត់ចំណាយប្រចាំត្រីមាស ឬឆមាសសម្រាប់គម្រោងចំណាយមូលធននីមួយៗបែបនេះ គប្បីត្រូវបានធ្វើឡើងនៅក្នុងពេលនៃការរៀបចំផែនការសាច់ប្រាក់របស់ក្រសួង ស្ថាប័ន និង **គបគស**។ ប្រសិនការចំណាយនៃខែនីមួយៗអាចមានការប្រែប្រួលក៏ដោយគឺក្រសួង ស្ថាប័ន និង **គបគស** ត្រូវធានាថា ការធានាចំណាយនោះ ត្រូវសមស្របទៅតាមថវិកាដែលបានអនុញ្ញាត។

ម្យ៉ាងទៀតគម្រោងចំណាយមូលធនបែបនេះ គឺតម្រូវឲ្យមានការធ្វើផែនការចំណាយជាដំណាក់ៗ តាមខែ តាមត្រីមាស តាមឆមាស និងតាមឆ្នាំនីមួយៗ ដើម្បីធានាថាផែនការចំណាយទាំងមូលត្រូវបានដឹងច្បាស់លាស់សម្រាប់ការធ្វើវិនិយោគនេះ។

ការងារនេះ គឺត្រូវរួមបញ្ចូលទាំងការប៉ាន់ស្មានអំពីតម្លៃសម្រាប់រយៈពេលទាំងមូលនៃគម្រោងនិងតម្រូវការលំហូរសាច់ប្រាក់សម្រាប់ពេលចាប់ផ្តើមអនុវត្តសំណើនីមួយៗ រហូតដល់មុនពេលចាប់ផ្តើមគម្រោង ហើយក៏រួមបញ្ចូលផងដែរនូវការព្យាករណ៍ប្រកបដោយភាពប្រាកដប្រជា និងការពិនិត្យឡើងវិញនូវការព្យាករណ៍ទាំងនេះ ដើម្បីធានាថាតម្រូវការត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ ហើយការធានាចំណាយសម្រាប់គម្រោងមូលធនអាចត្រូវបានធ្វើឡើងនិងត្រូវបានគោរពតាម។

**ង.** ក្រសួង ស្ថាប័នដែលមានចំណូលត្រូវព្យាករណ៍ប្រចាំខែអំពីចំណូលមិនមែនសារពើពន្ធរបស់ខ្លួនឬចំណូលដែលត្រូវបានផ្តល់ឲ្យដោយរាជរដ្ឋាភិបាលនៅក្នុងតារាងឧបសម្ព័ន្ធ២។ រាល់ចំណូលទាំងអស់គឺត្រូវបង់ចូលគណនីទោលរតនាគារ ដូចមាននៅក្នុងតារាងឧបសម្ព័ន្ធ២ និងរបាយការណ៍លទ្ធផលថវិកា។ ចំណូលមិនមែនសារពើពន្ធរួមមាន៖

- ផលពីការបង់សិទ្ធិប្រឡង
- អាជ្ញាប័ណ្ណអាជីវកម្មនិងវិជ្ជាជីវៈ
- ចំណូលពីប្រដាប់ក្តី.....។ល។

**ច.** ត្រូវយកចិត្តទុកដាក់ក្នុងការធ្វើព្យាករណ៍នេះប្រកបទៅដោយការប្រុងប្រយ័ត្ននិងត្រូវផ្សារភ្ជាប់ជាមួយនឹងគំរូនៃលំហូរសាច់ប្រាក់ដែលអាចកើតមានឡើង ហើយការព្យាករណ៍ទាំងនេះគប្បីត្រូវផ្សារភ្ជាប់ជាមួយនឹងលំហូរចូលសាច់ប្រាក់ជាក់ស្តែងដែលធ្លាប់កើតមានឡើងកន្លងមកដោយគិតទៅដល់រាល់ករណីពិសេសដែលអាចនាំឲ្យមាននូវការកើនឡើងឬការថយចុះនៃចំណូល។

ឆ. **គបគស** ត្រូវជូនដំណឹងដល់គ្រប់ក្រសួង ស្ថាប័នអំពីចំនួនសាច់ប្រាក់អតិបរមាប្រចាំខែដែលផ្អែកលើផែនការសាច់ប្រាក់ដែលបានអនុម័ត សម្រាប់ជាព័ត៌មាននៅមុនថ្ងៃទី១ ខែកញ្ញា រៀងរាល់ឆ្នាំ[4]។ បន្ទាប់មក ក្រសួង ស្ថាប័នត្រូវយកចំនួនសាច់ប្រាក់អតិបរមាប្រចាំខែទាំងនេះធ្វើជាមូលដ្ឋានដើម្បីធ្វើការបែងចែងសាច់ប្រាក់លំអិតទៅតាមអង្គភាពចំណាយនៅក្នុងករណីដែលអាចធ្វើទៅបាន។ ក្រសួង ស្ថាប័នត្រូវធានាថាការធានាចំណាយ [5] របស់ខ្លួននឹងមិនមានចំនួនលើសពីសាច់ប្រាក់ដែលមានសម្រាប់ខែនីមួយៗនោះទេ ទោះបីជាស្ថិតនៅក្នុងកាលៈទេសៈបែបណាក៏ដោយ។ ប៉ុន្តែក្នុងករណីមានតម្រូវការចំណាយសាច់ប្រាក់ដែលមានលក្ខណៈពិសេសឬបន្ទាន់ដែលក្រសួងស្ថាប័នមិនបានគ្រោងទុក ក្រសួងស្ថាប័នទាំងនោះត្រូវស្នើសុំសាច់ប្រាក់បន្ថែមពី **គបគស** ដោយមានការផ្តល់នូវយុត្តាធិការសមស្រប គ្រប់គ្រាន់និងអាស្រ័យទៅលើស្ថានភាពសាច់ប្រាក់ជាក់ស្តែង។

**ជំហានទី២:**

ក. អង្គភាពចំណាយទាំងឡាយដែលស្ថិតនៅក្រោមឱវាទរបស់ក្រសួងសាមី គួរត្រូវធ្វើការកំណត់អាទិភាពសម្រាប់គម្រោងកម្មវិធី ឬតម្រូវការចំណាយផ្សេងៗដែលអាចកើតមានឡើង។គម្រោងកម្មវិធី ឬតម្រូវការទាំងនោះ គប្បីត្រូវបានធ្វើចំណាត់ថ្នាក់ដូចខាងក្រោមនេះ៖

| **កម្រិតអាទិភាព** | **ការពិពណ៌នា** |
|---|---|
| ទី ១ | ប្រាក់បៀវត្សរ៍ លក្ខណៈជាបៀវត្សរ៍និងការសងបំណុល |
| ទី ២ | ចំណាយចាំបាច់និងចំណាយអាទិភាព - ការពន្យារពេលនឹងធ្វើឲ្យមានការប៉ះពាល់ធ្ងន់ធ្ងរដល់មុខងារសំខាន់ៗ របស់ក្រសួង ស្ថាប័ន ឬ អង្គភាពចំណាយ ឧ.ការបង់ប្រាក់សម្រាប់សេវាទឹក ភ្លើង ទូរស័ព្ទ អ៊ីនធឺណិត និង |

4 នឹងត្រូវបានបញ្ជាក់ឡើងវិញនៅពេលដែលថវិកាត្រូវបានអនុម័តដោយរដ្ឋសភា ។

5 ការធានាចំណាយគឺជាកាតព្វកិច្ចចំណាយដែលតម្រូវឲ្យរដ្ឋាភិបាលត្រូវទូទាត់នៅពេលអនាគត។ វាកើតមានឡើងនៅក្នុងពេលដែលសកម្មភាពជាផ្លូវការដូចជា ការជួលបុគ្គលិកឬការផ្តល់នូវកិច្ចសន្យាត្រូវបានធ្វើឡើងនិងដែលនាំឲ្យមានបំណុលភ្លាមៗ ឬអនាគតដែលត្រូវសងដោយរដ្ឋាភិបាល។ ការធានាចំណាយបែបនេះអាចមានពីរប្រភេទ៖ ការធានាចំណាយចរន្តដូចជា ប្រាក់បៀវត្សរ៍ ការបង់ថ្លៃសេវាប្រើប្រាស់ផ្សេងៗ ការសងបំណុល។ល។ ដែលមិនចាំបាច់ត្រូវការនូវកិច្ចសន្យាជាក់លាក់នោះទេនិងការធានាចំណាយដែលកើតមានឡើងដោយសារការមានកិច្ចសន្យាជាក់លាក់សម្រាប់ទំនិញនិងសេវាអាចជាប្រភេទធានាចំណាយមូលធនឬចរន្ត។

| | |
|---|---|
| | បេសកកម្មក្រៅប្រទេស។ល។ |
| ទី ៣ | ចំណាយអាទិភាពមធ្យម - ការពន្យារពេល អាចមានរយៈពេលមួយឬពីរខែ ដោយគ្មានការប៉ះពាល់ធ្ងន់ធ្ងរដល់មុខងារសំខាន់ៗរបស់ក្រសួង ស្ថាប័នឬអង្គភាពចំណាយ។ |
| ទី ៤ | ចំណាយដែលមានតាមករណីជាក់ស្តែងក្រៅពីអាទិភាពខាងលើ។ |

**ខ.** នៅក្នុងករណីសាច់ប្រាក់មានការខ្វះខាត ការបែងចែកសាច់ប្រាក់ត្រូវអនុវត្តទៅតាមតារាងចំណាយអាទិភាព ប៉ុន្តែមិនអនុញ្ញាតឲ្យផ្ទេរខ្ទង់ចំណាយបានទេ។ ការផ្ទេរខ្ទង់ចំណាយអាចធ្វើទៅបានក្នុងករណីដែលមានសេចក្តីសម្រេចដូចមានចែងនៅក្នុងសេចក្តីណែនាំឬប្រកាសតែប៉ុណ្ណោះ។ ក្រសួង ស្ថាប័នត្រូវយកចិត្តទុកដាក់លើការធានាឲ្យមានសាច់ប្រាក់គ្រប់គ្រាន់សម្រាប់ធានាចំណាយដែលមានស្រាប់ និងចំណាយរង់ចាំទូទាត់។ ក្រសួង ស្ថាប័នឬអង្គភាពចំណាយត្រូវផ្តល់ជូនអគ្គនាយកដ្ឋានរតនាគារជាតិនូវតារាងអាទិភាពនៃគម្រោងកម្មវិធី ឬតម្រូវការចំណាយនីមួយៗរបស់ខ្លួនក្រោយពីទទួលបានការអនុម័តពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ អង្គភាពចំណាយត្រូវផ្ញើផែនការសាច់ប្រាក់និងតារាងចំណាយអាទិភាពដែលមានការកែតម្រូវទៅក្រសួងស្ថាប័នវិញយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ខែកញ្ញាជារៀងរាល់ឆ្នាំ។

**ជំហានទី៣**: ក្រសួង ស្ថាប័ន ត្រូវធ្វើការពិនិត្យនិងផ្ទៀងផ្ទាត់នូវតម្រូវការលំហូរសាច់ប្រាក់និងតារាងចំណាយអាទិភាពបន្ទាប់ពីទទួលបានផែនការសាច់ប្រាក់ពីអង្គភាពចំណាយនីមួយៗ របស់ខ្លួនមករួចហើយ ត្រូវធ្វើការបូកសរុបរបាយការណ៍លំអិតនៃលំហូរចេញនិងលំហូរចូលនៃសាច់ប្រាក់ទៅតាមប្រភេទនីមួយៗ ដូចមាននៅក្នុងតារាងឧបសម្ព័ន្ធទី៣។ បន្ទាប់មកត្រូវផ្ញើទៅ **គបគស** យ៉ាងយឺតបំផុតត្រឹម**ថ្ងៃទី១៥ ខែវិច្ឆិកា នៃឆ្នាំនីមួយៗ**។

**ជំហានទី៤**:

**ក.** ក្នុងពេលជាមួយគ្នានេះក្រសួង ស្ថាប័នដែលមានចំណូលត្រូវបំពេញតារាងឧបសម្ព័ន្ធទី២ផងដែរ។ ការធ្វើដូច្នេះ គឺអាចធ្វើការវាយតម្លៃបានអំពីលំហូរសាច់ប្រាក់ដោយផ្ទាល់និងដោយប្រយោល។ តារាងឧបសម្ព័ន្ធនេះនឹងបន្ថែមពីលើតារាងឧបសម្ព័ន្ធទី៣ ដែលបង្ហាញអំពីតម្រូវការចំណាយរបស់ខ្លួន។

**ខ.** ចំពោះក្រសួង ស្ថាប័នដែលមានចំណូល គឺត្រូវបំពេញនៅក្នុងតារាងឧបសម្ព័ន្ធទី២ ដើម្បីបង្ហាញអំពីចំណូលរំពឹងទុកប្រចាំខែដែលត្រូវបានធ្វើការកែតម្រូវទៅតាមការប្រែប្រួលនៃរដូវកាលនិងការធ្លាប់អនុវត្តន៍កន្លងមក។ ក្រសួង ស្ថាប័នចំណូល ត្រូវវាយការណ៍តែអំពីចំណូលដែលខ្លួនប្រមូលបានប៉ុណ្ណោះ ហើយប្រធានក្រសួង ស្ថាប័ន ត្រូវធ្វើការពិនិត្យផ្ទៀងផ្ទាត់អំពីការព្យាករណ៍លំហូរចូលនៃសាច់ប្រាក់ទាំងនោះតាមរយៈការប្រៀបធៀបជាមួយនឹងគំរូនៃការប្រមូលនៅក្នុងពេលកន្លងមក។ ការព្យាករណ៍ដំបូងទាំងនេះត្រូវតែធ្វើ

ទៅកាន់ **គបគស** **<u>យ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ខែវិច្ឆិកា ជារៀងរាល់ឆ្នាំ</u>**។ ក្រោយការព្យាករណ៍ដំបូងត្រូវបានធ្វើរួចហើយនោះ ក្រសួង ស្ថាប័នចំណូលក៏ត្រូវធ្វើការកែតម្រូវទៅលើការព្យាករណ៍ទាំងនោះផងដែរ ដោយធ្វើការប្រៀបធៀបជាមួយនឹងការប្រមូលជាក់ស្តែងនិងធ្វើការបង្កើនឬកាត់បន្ថយទៅតាមស្ថានភាពជាក់ស្តែងរួចត្រូវផ្ញើទៅ **គបគស យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២៤ នៃខែនីមួយៗ**។

គ. ទិន្នន័យដែលមានការទាក់ទងទៅនឹងបំណុលនិងការធានាសងបំណុល ការវិនិយោគ ប្រាក់កក់ធានាដែលដល់កាលវសាន គឺត្រូវបានបំពេញដោយអគ្គនាយកដ្ឋានរតនាគារជាតិបន្ទាប់ពីទទួលបាននូវតារាងលំអិតដាច់ដោយឡែកទៅតាមការចាំបាច់ដោយប្រើប្រាស់នូវតារាងឧបសម្ព័ន្ធទី១ ហើយត្រូវផ្ញើទៅជូនប្រធាន **គបគស យ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ខែវិច្ឆិកា នៃឆ្នាំនីមួយៗ**។

**ជំហានទី៥: គបគស** ត្រូវទទួលបានរបាយការណ៍ពីក្រសួង ស្ថាប័នចំណូលទាំងអស់នូវផែនការសាច់ប្រាក់សម្រាប់ឆ្នាំសារពើពន្ធបន្ទាប់ **យ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ខែវិច្ឆិកា នៃឆ្នាំនីមួយៗ**។

**ជំហានទី៦: គបគស** ត្រូវប្រើប្រាស់នូវផែនការសាច់ប្រាក់(ផ្អែកលើរបាយការណ៍នៃផែនការសាច់ប្រាក់របស់ក្រសួងស្ថាប័នដែលបានផ្ញើមកដូចក្នុងតារាងឧបសម្ព័ន្ធទី៣) ក្នុងការបូកសរុបទិន្នន័យស្តីអំពីលំហូរចូលនិងលំហូរចេញនៃសាច់ប្រាក់បញ្ចូលទៅក្នុងតារាងឧបសម្ព័ន្ធទី១ ដើម្បីទទួលបានលំហូរសាច់ប្រាក់សរុបគ្រាដំបូងរបស់រាជរដ្ឋាភិបាលសម្រាប់ឆ្នាំបន្ទាប់ដែលបង្កើតបានជាតារាងឧបសម្ព័ន្ធទី៤ យ៉ាងយឺតបំផុត **ត្រឹមថ្ងៃទី១៥ ខែធ្នូ នៃឆ្នាំនីមួយៗ**។

**ជំហានទី៧: គបគស** ត្រូវផ្ញើរបាយការណ៍ស្ថានភាពនៃការបូកសរុបលំហូរសាច់ប្រាក់របស់ក្រសួង ស្ថាប័ន (ផែនការសាច់ប្រាក់ប្រចាំឆ្នាំ) ទៅជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងផ្ញើច្បាប់ចម្លងទៅជូនប្រធានគណៈកម្មាធិការតាមដានការអនុវត្តន៍ថវិកានិងគ្រប់គ្រងសាច់ប្រាក់ ដើម្បីអាចធ្វើការកំណត់អំពីដែនកំណត់អតិបរមាទូទៅនៃសាច់ប្រាក់ប្រចាំខែសម្រាប់ក្រសួង ស្ថាប័ននីមួយៗសម្រាប់ឆ្នាំទាំងមូលនិងដាក់បញ្ចូលទៅក្នុងថវិកាមុនពេលដាក់ជូនសុំការអនុម័តពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **យ៉ាងយឺតបំផុតត្រឹមថ្ងៃទី១០ខែធ្នូ នៃឆ្នាំនីមួយៗ**។ បន្ទាប់មក ការកម្រិតសាច់ប្រាក់ទាំងនេះអាចឲ្យគេយកមកធ្វើជាលំនាំសម្រាប់ការបញ្ចេញសាច់ប្រាក់ប្រចាំខែរយៈពេលពេញមួយឆ្នាំ លើកលែងតែក្នុងករណីមានការកែតម្រូវទៅតាមនីតិវិធីដែលត្រូវបានចែង។ ការបែងចែកសាច់ប្រាក់អាទិភាពអន្តរវិស័យរវាងក្រសួង ស្ថាប័នដែលមានការពាក់ព័ន្ធ គឺត្រូវអនុវត្តផ្អែកលើភារកិច្ចជាអាទិភាពរបស់ក្រសួង ស្ថាប័ននីមួយៗទៅតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ប៉ុន្តែ នៅក្នុងពេលធ្វើការបែងចែកសាច់ប្រាក់ប្រចាំខែទៅឲ្យក្រសួង ស្ថាប័ន អគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវរក្សាទុកនូវសាច់ប្រាក់បម្រុងមួយចំនួនមិនឲ្យលើសពី៣% នៃសាច់ប្រាក់សរុបដែលមានដើម្បីអាចធ្វើការដោះស្រាយចំពោះរាល់តម្រូវការបន្ទាន់និងគ្មានការគ្រោងទុករបស់ក្រសួង ស្ថាប័ន។

**ជំហានទី៨:** រាល់ការកែតម្រូវទាំងឡាយណាដែលបានធ្វើឡើងដោយនាយកដ្ឋានថវិកា(ជំហាន៧) សម្រាប់ឆ្លុះបញ្ចាំងអំពីអាទិភាពដែលត្រឹមត្រូវនិងជាក់លាក់របស់រាជរដ្ឋាភិបាល នឹងត្រូវបានជូនដំណឹងទៅក្រសួង ស្ថាប័នពាក់ព័ន្ធជាមួយនឹងការកម្រិតសាច់ប្រាក់។ **គបគស** ត្រូវធានាថាការបញ្ចេញសាច់ប្រាក់របស់ខ្លួនត្រូវបានអនុវត្តដោយទាន់ពេលវេលា និងមិនមានការរាំងស្ទះដោយប្រការណាមួយឡើយ។

**ជំហានទី៩: គបគស** ត្រូវផ្ញើផែនការសាច់ប្រាក់ប្រចាំឆ្នាំនិងយោបល់របស់ខ្លួនស្ដីអំពីការបើកសាច់ប្រាក់ទៅឲ្យក្រសួង ស្ថាប័ននីមួយៗ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **យ៉ាងយឺតបំផុតត្រឹមថ្ងៃទី១០ ខែធ្នូនៃឆ្នាំនីមួយៗ** ដើម្បីសុំការសម្រេចនិងផ្ញើជូនក្រសួង ស្ថាប័នសារជាថ្មីបន្ទាប់ពីមានការកែតម្រូវ។ យោបល់ស្ដីអំពីការបើកសាច់ប្រាក់ទៅឲ្យក្រសួង ស្ថាប័នត្រូវបានកែតម្រូវឲ្យស្របទៅតាមនីតិវិធីដូចមានចែងនៅក្នុងគោលការណ៍ណែនាំនេះ។

**ជំហានទី១០:** ក្នុងពេលជាមួយគ្នានេះ **គបគស** ក៏ត្រូវផ្ញើជូនផងដែរនូវច្បាប់ចម្លងនៃផែនការសាច់ប្រាក់ប្រចាំឆ្នាំដែលខ្លួនមាន ទៅឲ្យនាយកដ្ឋានថវិកានិងផ្នែកពាក់ព័ន្ធនានានៅក្នុងអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីអាចឲ្យគេធ្វើការត្រួតពិនិត្យតាមដាននូវលំហូរចូលនិងលំហូរចេញនៃសាច់ប្រាក់ប្រៀបធៀបជាមួយនឹងសមតុល្យសាច់ប្រាក់នៅក្នុងគណនីទោលរតនាគារនៅធនាគារជាតិនៃកម្ពុជា និងធ្វើការកំណត់អំពីសមតុល្យសាច់ប្រាក់របស់រាជរដ្ឋាភិបាល។ នាយកដ្ឋានគណនេយ្យនៃអគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវធ្វើការពិនិត្យតាមដានរបាយការណ៍ស្ដីពីស្ថានភាពសាច់ប្រាក់ប្រចាំថ្ងៃនៅក្នុងគណនីទោលរតនាគារនៅធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើជាមូលដ្ឋានក្នុងការផ្ដល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការសម្រេចអំពីតម្រូវការនៃការខ្ចីរបស់រដ្ឋ។

**ជំហានទី១១:** ការបើកផ្ដល់សាច់ប្រាក់ជាក់ស្ដែងត្រូវបានធ្វើការត្រួតពិនិត្យប្រចាំសប្ដាហ៍ និងប្រចាំខែដោយប្រើប្រាស់តារាងលំហូរសាច់ប្រាក់និងតារាងស្ថានភាពសាច់ប្រាក់ប្រចាំខែរបស់រដ្ឋ ដូចមាននៅក្នុងតារាងឧបសម្ព័នទី៥កនិងទី៥ខ ដើម្បីធានាថាក្រសួងស្ថាប័នបានទទួលនូវសាច់ប្រាក់។ ប្រសិនបើមានការបើកផ្ដល់ប្រាក់មិនទាន់បានគ្រប់ចំនួនទេនោះ គឺត្រូវបំពេញឡើងវិញនៅពេលមានសាច់ប្រាក់គ្រប់គ្រាន់។ យោបល់បែបនេះត្រូវធ្វើឡើងដោយ **គបគស** តាមរយៈការប្រើប្រាស់តារាងស្ថានភាពសាច់ប្រាក់ប្រចាំសប្ដាហ៍ដូចមានក្នុងតារាងឧបសម្ព័ន្ធទី៦។ តារាងឧបសម្ព័ន្ធទី៦នេះ គឺត្រូវបានរៀបចំឡើងសម្រាប់សប្ដាហ៍កំពុងដំណើរការនិងសម្រាប់បីសប្ដាហ៍បន្ទាប់ ដើម្បីបង្កើតបាននូវរបាយការណ៍លំហូរសាច់ប្រាក់និងតម្រូវការសាច់ប្រាក់។ ការរៀបចំនេះគឺត្រូវធ្វើឡើងរៀងរាល់សប្ដាហ៍[6] នៅក្នុងដំណាក់កាលដំបូង។ ជាដំបូង **គបគស** ត្រូវចាប់ផ្ដើមធ្វើការកំណត់សមតុល្យជាក់ស្ដែងនៅក្នុងគណនីទោល

[6] សូមមើលកំណត់សម្គាល់លេខ៨ខាងលើ។

រតនាគារនៅធនាគារជាតិនៃកម្ពុជា។ ចំណូលសាច់ប្រាក់ដែលក្រសួងស្ថាប័នសាមី[7]ប្រមូលផ្ទាល់នោះ ក៏ត្រូវធ្វើការព្យាករណ៍ជាមួយគ្នានឹងតម្រូវការសាច់ប្រាក់ ហើយសមតុល្យដែលមានក៏ត្រូវប៉ាន់ប្រមាណផងដែរ។ ក្នុងករណីស្ថានភាពសាច់ប្រាក់មានការលំបាកការបញ្ចេញសាច់ប្រាក់ក៏ត្រូវមានវិធានការកាត់បន្ថយផងដែរ។ **គបគស** ត្រូវធ្វើការតាមដានជាប់ជាប្រចាំនូវស្ថានភាពគណនីទោលរតនាគារជាប្រាក់រៀលនិងប្រាក់ដុល្លារដើម្បីរក្សាស្ថានភាពសមតុល្យសរុបរបស់គណនីទោលទាំងពីរ(គណនីប្រាក់រៀល និងដុល្លារ) ឲ្យស្ថិតនៅក្នុងចន្លោះពី ១០០ពាន់លានរៀល ទៅ៣០០ពាន់លានរៀល។ ប្រសិនបើសមតុល្យនៅក្នុងគណនីទោលរតនាគារមានសាច់ប្រាក់លើសការកម្រិតកំណត់ខាងលើនេះ គឺត្រូវគិតបញ្ចូលទៅក្នុងសមតុល្យដើមគ្រានៅក្នុងតារាងឧបសម្ព័ន្ធទី៦។ ដោយផ្អែកទៅលើសមតុល្យដែលមាន **គបគស** ត្រូវធ្វើការផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អំពីកម្រិតនៃការបញ្ចេញសាច់ប្រាក់នៅក្នុងខែបន្ទាប់។ បន្ទាប់មកការបញ្ចេញសាច់ប្រាក់ទាំងនេះនឹងធ្វើជាលំនាំដល់ក្រសួងស្ថាប័នក្នុងការកំណត់អំពីទំហំនៃការចំណាយដែលនឹងត្រូវធ្វើឡើងនៅក្នុងខែនោះរហូតដល់ការបញ្ចេញសាច់ប្រាក់លើកបន្ទាប់ដែលត្រូវបានកំណត់ដោយ **គបគស**។ យោបល់សម្រាប់ការកាត់បន្ថយការបញ្ចេញសាច់ប្រាក់ត្រូវធ្វើឡើងក្នុងករណីដែលរំពឹងទុកថានឹងមានសមតុល្យអវិជ្ជមាន។ **គបគស** នឹងធ្វើការតាមដានស្ថានភាពគណនីទោលរតនាគារជាប្រាក់រៀល(លេខ០០០០០០០០១១១១) និងជាប្រាក់ដុល្លារ(លេខ០០០០០០០០១៣៣៣) នៅធនាគារជាតិនៃកម្ពុជាដើម្បីធានាថាសមតុល្យអប្បបរមានិងសមតុល្យអតិបរមាសម្រាប់គណនីទោលរតនាគារត្រូវបានកម្រិតឲ្យស្ថិតនៅចន្លោះពី ១០០ ពាន់លានរៀល ទៅ ៣០០ពាន់លានរៀល។ នៅពេលដែលសមតុល្យនៃគណនីទោលរតនាគារបានឡើងដល់កម្រិតកំណត់រួចហើយនោះ សមតុល្យទាំងនេះនឹងត្រូវដាក់បញ្ចូលទៅក្នុងសមតុល្យដើមគ្រាដូចមាននៅក្នុងតារាងឧបសម្ព័ន្ធទី៦[8]។

**ជំហានទី១២:** អគ្គនាយកដ្ឋានរតនាគារជាតិនឹងប្រើប្រាស់របាយការណ៍របស់ **គបគស** ទាំងនេះដោយធ្វើការប្រៀបធៀបជាមួយនឹងរបាយការណ៍ចំណាយជាក់ស្តែងរៀងរាល់សប្តាហ៍ ដើម្បីធានាថាការចំណាយមិនមានចំនួនលើសពីការបែងចែកឡើយ។ ក្រសួង ស្ថាប័នត្រូវធានាថា គ្មានការចំណាយណាមួយរួមទាំងការធានាចំណាយនិងការបម្រុងទុកលើសកម្រិតសាច់ប្រាក់ដែលមានសម្រាប់ខែជាក់លាក់នោះទេ ប្រសិនបើមានចំនួនលើស គឺត្រូវធ្វើការពន្យល់អំពីមូលហេតុនៃការលើសនោះ។ ការងារនេះ គឺត្រូវមានការទទួលខុសត្រូវដោយផ្ទាល់របស់ក្រសួង ស្ថាប័នសាមី។

---

7 ផ្អែកលើផែនការសាច់ប្រាក់របស់ក្រសួង ស្ថាប័នសាមី។

8 គប្បីត្រូវធានាថាសាច់ប្រាក់ដែលស្ថិតនៅក្នុងគណនីមូលនិធិបុរេប្រទាន ទោះបីជានៅក្នុងប្រទេសឬក្រៅប្រទេសក្តី នឹងត្រូវបានរក្សាឲ្យស្ថិតនៅក្នុងកម្រិតអប្បបរមានិងនៅក្នុងគណនីបុរេប្រទាន មុនពេលដែលបុរេប្រទានថ្មីត្រូវបានអនុញ្ញាតិឲ្យធ្វើឡើង។

